# សិលាចារឹកលើទម្រពុទ្ធបដិមានៅភ្នំតូច (អង្គរបុរី ខេត្តតាកែវ)

*កាលពីខែមិថុនា ឆ្នាំ២០១៨ មានការប្រទះឃើញព្រះពុទ្ធរូបមួយអង្គនៅតំបន់ភ្នំតូច ស្រុកអង្គរបុរី ខេត្តតាកែវ និងក្រោយមកគេបានយកបដិមានេះទៅរក្សាទុកនិងដាក់តាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា។ ព្រះពុទ្ធរូបនេះ ធ្វើអំពីថ្មភក់ ស្ថិតនៅក្នុងទម្រង់ឈរត្រង់ ក្នុងកាយ**វិការ "វិតក៌មុទ្រា"** ដែលគេស្គាល់ថាជាកាយវិការនៃការពិភាក្សា ការពន្យល់ ឬការបង្រៀនធម៌ទៅកាន់សត្វលោក។ គួរឱ្យចាប់អារម្មណ៍ ទម្រខាងក្រោមនៃព្រះពុទ្ធទ្រង់ឈរនេះ មានចារអក្សរថែមទៀតផង។ តើសិលាចារឹកនៅលើទម្រពុទ្ធបដិមានៅភ្នំតូច មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្តេចខ្លះ?*

*អត្ថបទសិលាចារឹកនេះ សរសេរជាភាសាបាលិ តែក្នុងទម្រង់ជាភាសាបាលិដែលមានឥទ្ធិពលពីភាសាសំស្រ្កឹតខ្លះៗ ព្រោះជាទូទៅនៅកម្ពុជាបុរាណនិយមភាសាសំស្រ្កឹតជាងភាសាបាលិ។ អក្សរចារឹកនេះ មានចំនួន ៣ បន្ទាត់ ហើយបើយោងទៅលើរូបរាងនិងលក្ខណៈនៃអក្សរ គឺមានអាយុកាលស្ថិតនៅចុងស.វ.ទី៦ ឬដើមស.វ.ទី៧ ពោល គឺដំណាលគ្នាជាមួយព្រះពុទ្ធទ្រង់ឈរនេះតែម្តង។ អត្ថបទនេះ គឺជាប្រភេទគាថាដែលជាគោលសំខាន់ស្តីពីព្រះពុទ្ធសាសនា និកាយថេរវាទ ឬហិនយាន។ ខ្លឹមសារចម្បងរបស់អក្សរចារឹកនេះ គឺរៀបរាប់អំពីម្ចាស់ទាននៃអ្នកកសាងព្រះពុទ្ធអង្គទ្រង់ឈរ និងអ្នកដែលម្ចាស់ទានឧទ្ទិសដល់។ ជាពិសេស គឺរៀបរាប់អំពីទ្រឹស្តីរបស់ព្រះអរហន្តសាក្យមុនីសម្ពុទ្ធ ដែលទាក់ទងនឹងអរិយសច្ចធម៌ ឬហៅថាទ្រឹស្តីបដិច្ចសមុប្បាទ។*

**អត្ថបទចារឹក**

១.	ភកវាញ្ញក្យមុដិ

២.	ជម្មំម្មតរាជជាម្នា ស្តីវំរេណាក្ម្មតាមុនេរិយំ ប្រតិមា ស្តីវីម្នាតុលមតុល ភជន្តដិឯក ទ្រមុទ្ធិត្យ។

៣.	ទុះ+ខខះខសមុប្បាគោ ទុះខស្ស ច អតិក្រមោ អបរោចដ្ឋង្គិកោមគ្គោ ខេមោបគ មគាមិកោ។

*អត្ថបទដោយៈ កំ វណ្ណារ៉ា*

## អត្ថបទសម្រួល

(១-២) ភគវាញ្ញក្យមុនិ ជម្មាំម្មូតរាជជាម្នា ស្ថវីរេណាក្មូតាមុនេរិ ឥយំ ប្រតិមា ស្ថវីរមិ មាតុលមិ អតុលមិ ភជន្តជិនកទ្រមិ ឧទ្ទិត្យ។

៣. ទុះ+ខទុះខសមុប្បាទោ
ទុះខស្ស ច អតិក្រាមោ
អបពោចជ្ឋក្តិកោមក្តោ
ខេមោបគមតាមិកោ។

## សេចក្តីប្រែ

*ព្រះបដិមាព្រះភគវ័នៃសាក្យមុនីសម្ពុទ្ធ បានស្ថាបនាឡើងដោយព្រះស្ថវីរៈ (ព្រះថេរៈ) មាននាមថា "**ធម្មុំម្មូគរាជ**" ដើម្បីឧទ្ទិសដល់ ព្រះតេជគុណភទន្តជិនកទ្រ ដែលជាមាតុលៈ (ឪពុកមាខាងម្តាយ) ដែលជាអ្នកមានគុណរកអ្វីប្រៀបផ្ទឹមពុំបាន។*

*[ព្រះពុទ្ធអង្គទ្រង់សម្តែងថា]៖ សេចក្តីទុក្ខ (ទុក្ខអរិយសច្ច) ហេតុដែលនាំឱ្យកើតទុក្ខ (សមុទយអរិយសច្ច) ការកន្លងផុតនូវសេចក្តីទុក្ខ (និរោធអរិយសច្ច) និងផ្លូវដ៏ប្រសើរមានអង្គ ៨ ផ្សេងទៀត (អរិយមគ្គ) ដែលជាផ្លូវនាំទៅរកសេចក្តីក្សេមក្សាន្ត និងការរលត់ទុក្ខ ។*

*សរុបជារួមមក សិលាចារឹកលើពុទ្ធបដិមារកឃើញនៅភ្នំតូច ស្រុកអង្គរបុរី ខេតត្តាកែវ កាលពីខែមិថុនា ឆ្នាំ២០១៨ បានផ្តល់ព័ត៌មានដ៏សំខាន់ពាក់ព័ន្ធជាមួយនាមម្ចាស់ទានដែលជាអ្នកស្ថាបនាព្រះពុទ្ធទ្រង់ឈរនេះឡើង (ធម្មុំម្មូគរាជ) និងនាមដែលម្ចាស់ទានឧទ្ទិសដល់ (ភទន្តជិនកទ្រ)។ ព្រមជាមួយគ្នានេះ ក៏បានរៀបរាប់អំពីធម៌អរិយសច្ចទាំង ៤ និងផ្លូវដ៏ប្រសើរទាំង ៨ នៃព្រះពុទ្ធអង្គផងដែរ។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*




រូបលេខ១-២៖ ព្រះពុទ្ធទ្រង់ឈររកឃើញនៅភ្នំតូច អង្គរបុរី តាកែវ (មើលពីមុខត្រង់ និងចំហៀងស្តាំ)
(សព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ)

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ២៣៖ អក្សរចារឹកនៅលើទម្របដិមាព្រះពុទ្ធទ្រង់ឈររកឃើញនៅភ្នំតូច អង្គរបុរី តាកែវ




រូបលេខ២៤៖ សំណៅផ្ដិតអក្សរចារឹកនៅលើទម្របដិមាព្រះពុទ្ធទ្រង់ឈររកឃើញនៅភ្នំតូច អង្គរបុរី
(ផ្ដិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា